ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១៤៥០ សហវ

ប្រកាស
ស្តីពី
ការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យ
របស់បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១០៨/០៣៩ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៨ ស្តីពីរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ/បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីការបង្កើតបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ៧៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ ស្តីពីការកំណត់អត្រាភាគទានសម្រាប់ទ្រទ្រង់បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល

- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញសេចក្តីសម្រេចលេខ ១៣ ក្រ/ប.ជ.ស./កណហ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៣ របស់ក្រុមប្រឹក្សាភិបាលនៃបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់ប្រធានក្រុមប្រឹក្សាភិបាលនៃបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល

សម្រេច

ប្រការ ១ : ត្រូវបានដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យដើម្បីគ្រប់គ្រងមូលនិធិសម្រាប់ទ្រទ្រង់បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ដោយចែកចេញជា ថ្នាក់ ជំពូក គណនី និងអនុគណនី ដែលមានភ្ជាប់ជាឧបសម្ព័ន្ធ ដូចខាងក្រោម÷

១. ឧបសម្ព័ន្ធ ១ ជាប្លង់គណនេយ្យរបស់បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល

២. ឧបសម្ព័ន្ធ ២ ជាប្រព្រឹត្តិកម្មគណនីនៃប្លង់គណនេយ្យរបស់បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល

ប្រការ ២ : ការគ្រប់គ្រងគណនេយ្យរបស់បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិលត្រូវផ្អែកតាមប្រព័ន្ធគណនេយ្យបង្គរ។ ការអនុវត្តន៍ប្រព័ន្ធគណនេយ្យនេះគឺត្រូវធ្វើជាជំហានៗទៅតាមស្ថានភាពជាក់ស្តែង។

ប្រការ ៣ : បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិលត្រូវរៀបចំបង្កើតបន្ថែមអនុគណនីរង ដើម្បីបម្រើឱ្យកិច្ចបញ្ជិកានិងធ្វើរបាយការណ៍ទៅតាមតម្រូវការចាំបាច់។

ប្រការ ៤ : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

ប្រការ ៥ : ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តជាកិច្ចការប្រញាប់ ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៤ តទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ២០១៣

រដ្ឋមន្ត្រី

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ចម្លងជូន ÷
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងមុខងារសាធារណៈ
- គ្រប់ក្រសួង-ស្ថាប័ន
- ក្រុមប្រឹក្សាភិបាលនៃប.ជ.ស.
- សាលារាជធានី-ខេត្ត

" ដើម្បីជូនជ្រាប "

- គ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល

" ដើម្បីអនុវត្ត "

- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ឧបសម្ព័ន្ធ ១

តារាងមាតិកាគណនី នៃប្លង់គណនេយ្យរបស់បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល

លេខគណនី			ឈ្មោះគណនី	ក្រឹត	ថយ	សមតុល្យ
ថ្នាក់ ១ : គណនី មូលធន						
10	មូលធន និងធនបំរុង					
	101		ទាយជ្ជទាន	ឥណទាន	ឥណពន្ធ	ឥណទាយី
	106		អតិរេកផ្តែកចរន្តប្រើសម្រាប់ចំណាយវិនិយោគ	ឥណទាន	ឥណពន្ធ	ឥណទាយី
11	យោងជាថ្មី					
	110		យោងជាថ្មី ឥណទាយី (អតិរេក)	ឥណទាន	ឥណពន្ធ	ឥណទាយី
12	លទ្ធផលនៃការិយបរិច្ឆេទ (អតិរេក-ឱនភាព)					
	121		លទ្ធផលនៃការិយបរិច្ឆេទ	ឥណទាន ឥណពន្ធ	ឥណពន្ធ ឥណទាន	ឥណទាយី ឥណយិក
ថ្នាក់ ២ : គណនី អចលកម្ម						
20	អចលកម្មអរូបី					
	203		សោហ៊ុយសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍	ឥណពន្ធ	ឥណទាន	ឥណយិក
	205		ប្រកាសនីយបត្រ អាជ្ញាបណ្ណ និងសិទ្ធិប្រហាក់ប្រហែល	ឥណពន្ធ	ឥណទាន	ឥណយិក
21	អចលកម្មរូបី					
	211		ដីធ្លី ដីរ៉ែ និង សម្បត្តិធម្មជាតិផ្សេង១	ឥណពន្ធ	ឥណទាន	ឥណយិក
		2111	ដីធ្លី	ឥណពន្ធ	ឥណទាន	ឥណយិក
	212		ការរៀបចំកែលម្អ ដីធ្លី ដីរ៉ែ និងសម្បត្តិធម្មជាតិផ្សេង១	ឥណពន្ធ	ឥណទាន	ឥណយិក
		2121	ការរៀបចំកែលម្អ ដីធ្លី	ឥណពន្ធ	ឥណទាន	ឥណយិក
	213		សំណង់ និងការរៀបចំកែលម្អ អគារ	ឥណពន្ធ	ឥណទាន	ឥណយិក
		2131	អគារ	ឥណពន្ធ	ឥណទាន	ឥណយិក
		2132	ការរៀបចំ កែលម្អអគារ	ឥណពន្ធ	ឥណទាន	ឥណយិក
		2138	សំណង់ ផ្សេង១	ឥណពន្ធ	ឥណទាន	ឥណយិក
	215		បំបនកម្ម បច្ចេកទេស សំភារៈ និងហត្ថបករណ៍	ឥណពន្ធ	ឥណទាន	ឥណយិក
		2151	បំបនកម្ម បច្ចេកទេស	ឥណពន្ធ	ឥណទាន	ឥណយិក
		2152	សម្ភារៈ	ឥណពន្ធ	ឥណទាន	ឥណយិក
		2153	គ្រឿងឧបករណ៍ (ហត្ថបករណ៍)	ឥណពន្ធ	ឥណទាន	ឥណយិក
	218		អចលកម្មរូបី ផ្សេង១	ឥណពន្ធ	ឥណទាន	ឥណយិក
		2181	សម្ភារៈ ឧបករណ៍ដឹកជញ្ជូន	ឥណពន្ធ	ឥណទាន	ឥណយិក
		2182	សម្ភារៈ ឧបករណ៍ការិយាល័យ	ឥណពន្ធ	ឥណទាន	ឥណយិក
		2183	សម្ភារៈពត៌មានវិទ្យា និងទូរគមនាគមន៍	ឥណពន្ធ	ឥណទាន	ឥណយិក

ផ្ទះលេខ ៥២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
No 52, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
ទូរស័ព្ទ : ៨៥៥-២៣-៧២៨ ៦៦៨ ទូរសារ : ៨៥៥-២៣-៤២៧ ៧៥៥
Phone : 855-23-724 664 Fax : 855-23-427 708

		2184	សង្ហារឹម	ឥណពន្ធ	ឥណទាន	ឥណាយិក
		2188	ផ្សេងៗ	ឥណពន្ធ	ឥណទាន	ឥណាយិក
23	អចលកម្មកំពុងដំណើរការ					
	231		អចលកម្មកំពុងដំណើរការ	ឥណពន្ធ	ឥណទាន	ឥណាយិក
		2312	ការកែលម្អ ដីធ្លី	ឥណពន្ធ	ឥណទាន	ឥណាយិក
		2313	អគារ	ឥណពន្ធ	ឥណទាន	ឥណាយិក
		2315	បំបនកម្ម បច្ចេកទេស	ឥណពន្ធ	ឥណទាន	ឥណាយិក
26	ភាគកម្ម និងឥណទេយ្យពាក់ព័ន្ធ					
	261		មូលបត្រនៃភាគកម្ម	ឥណពន្ធ	ឥណទាន	ឥណាយិក
27	អចលកម្មបរិវណ្ណវត្ថុផ្សេងៗ					
	271		ការឱ្យខ្ចី	ឥណពន្ធ	ឥណទាន	ឥណាយិក
28	រំលស់អចលកម្ម					
	280		រំលស់អចលកម្មអរូបី	ឥណទាន	ឥណពន្ធ	ឥណទាយី
	281		រំលស់អចលកម្មរូបី	ឥណទាន	ឥណពន្ធ	ឥណទាយី
ថ្នាក់ ៤ : គណនី តតីយជន						
40	អ្នកផ្គត់ផ្គង់					
	401		អ្នកផ្គត់ផ្គង់ ទំនិញ សេវា ការងារ	ឥណទាន	ឥណពន្ធ	ឥណទាយី
	404		អ្នកផ្គត់ផ្គង់អចលកម្ម	ឥណទាន	ឥណពន្ធ	ឥណទាយី
	407		ការកាត់ទុក ការធានាស់	ឥណទាន	ឥណពន្ធ	ឥណទាយី
	409		អ្នកផ្គត់ផ្គង់ ឥណាយិក	ឥណទាន	ឥណពន្ធ	ឥណទាយី
42	បុគ្គលិក					
	421		ប្រាក់បៀវត្ស និងលាភការត្រូវសង	ឥណទាន	ឥណពន្ធ	ឥណទាយី
	422		សោហ៊ុយបេសកកម្ម និងសោហ៊ុយផ្សេងៗត្រូវសង	ឥណទាន	ឥណពន្ធ	ឥណទាយី
46	ឥណាយិក ឥណទាយី ផ្សេងៗ					
	462		ប្រាក់តម្កល់ធានាលើទីផ្សារសាធារណៈ	ឥណទាន	ឥណពន្ធ	ឥណទាយី
	463		ឥណាយិកផ្សេងៗ	ឥណទាន	ឥណពន្ធ	ឥណទាយី
	465		ឥណទាយីផ្សេងៗ	ឥណទាន	ឥណពន្ធ	ឥណទាយី
47	គណនី ចម្ងង ឬគណនីរង់ចាំ					
	470		ចំណូលត្រូវនិយ័តភាព	ឥណទាន	ឥណពន្ធ	ឥណទាយី
		470.8	ចំណូលផ្សេងៗ និងបង្វែររង់ចាំដោះស្រាយ	ឥណទាន	ឥណពន្ធ	ឥណទាយី
	472		ចំណាយរង់ចាំនិយ័តកម្ម	ឥណទាន	ឥណពន្ធ	ឥណទាយី
		472.8	ចំណាយផ្សេងៗ រង់ចាំដោះស្រាយ	ឥណទាន	ឥណពន្ធ	ឥណទាយី
	473		ចំណាយជាបណ្តោះអាសន្ន (បុរេប្រទានសាច់ប្រាក់) សម្រាប់ដំណើរការ	ឥណពន្ធ	ឥណទាន	ឥណាយិក
	474		ចំណូលបានទទួលពុំទាន់មានសលាកបត្រ	ឥណទាន	ឥណពន្ធ	ឥណទាយី
ថ្នាក់ ៥ : គណនី ហិរញ្ញវត្ថុ						
51	ធនាគារ-រតនាគារ					
	510		គណនីចរន្តនៅធនាគារជាតិនៃកម្ពុជា និងនៅសាខា	ឥណពន្ធ	ឥណទាន	ឥណាយិក
	511		មូលប្បទានបត្រធ្វើចេញាធិច្ច័យ	ឥណពន្ធ	ឥណទាន	ឥណាយិក
	512		មូលប្បទានបត្របានបោះផ្សាយ	ឥណពន្ធ	ឥណទាន	ឥណាយិក

	515		ប្រាក់បញ្ញើរបស់គ្រឹះស្ថានសាធារណៈនៅរតនាគារ	ឥណពន្ធ	ឥណទាន	ឥណយិក
	517		គណនីចរន្តនៅធនាគារពាណិជ្ជ និងនៅសាខា	ឥណពន្ធ	ឥណទាន	ឥណយិក
	519		បុរេប្រទានត្រូវសង	ឥណពន្ធ	ឥណទាន	ឥណយិក
53	បេឡាសាច់ប្រាក់					
	532		បេឡាសាច់ប្រាក់	ឥណពន្ធ	ឥណទាន	ឥណយិក
54	រដ្ឋទេយ្យបុរេប្រទាន					
	543		រដ្ឋទេយ្យករបុរេប្រទាន	ឥណពន្ធ	ឥណទាន	ឥណយិក
ថ្នាក់ ៦ : គណនី ចំណាយ						
60	ការទិញ					
	601		សម្ភារៈផ្គត់ផ្គង់ ថែទាំ	ឥណពន្ធ	ឥណទាន	ឥណយិក
		6011	សម្ភារៈផ្គត់ផ្គង់សំអាត និងអនាម័យ	ឥណពន្ធ	ឥណទាន	ឥណយិក
		6012	សម្ភារៈផ្គត់ផ្គង់សម្រាប់ថែទាំអគារ	ឥណពន្ធ	ឥណទាន	ឥណយិក
		6014	សម្ភារៈផ្គត់ផ្គង់សម្រាប់ថែទាំសម្ភារៈឧបករណ៍	ឥណពន្ធ	ឥណទាន	ឥណយិក
		6015	ប្រេងឥន្ធនៈ និងប្រេងរំអិល	ឥណពន្ធ	ឥណទាន	ឥណយិក
	602		សម្ភារៈផ្គត់ផ្គង់ផ្ទៃករដ្ឋបាល	ឥណពន្ធ	ឥណទាន	ឥណយិក
		6021	សម្ភារៈការិយាល័យ និងការបោះពុម្ព	ឥណពន្ធ	ឥណទាន	ឥណយិក
		6022	ស្បៀវភៅមើល និងឯកសារ	ឥណពន្ធ	ឥណទាន	ឥណយិក
		6028	ផ្សេងៗ	ឥណពន្ធ	ឥណទាន	ឥណយិក
	604		សំលៀកបំពាក់ និងការតុបតែង	ឥណពន្ធ	ឥណទាន	ឥណយិក
		6041	ឯកសណ្ឋាន	ឥណពន្ធ	ឥណទាន	ឥណយិក
		6048	ផ្សេងៗ	ឥណពន្ធ	ឥណទាន	ឥណយិក
	605		សម្ភារៈតូចតាច សង្ហារឹម និងសម្ភារៈបរិក្ខារ	ឥណពន្ធ	ឥណទាន	ឥណយិក
		6051	សម្ភារៈ និងបរិក្ខារបច្ចេកទេស	ឥណពន្ធ	ឥណទាន	ឥណយិក
		6052	សង្ហារឹម	ឥណពន្ធ	ឥណទាន	ឥណយិក
		6053	សម្ភារៈប្រើប្រាស់	ឥណពន្ធ	ឥណទាន	ឥណយិក
		6054	សម្ភារៈ និងឧបករណ៍ដឹកជញ្ជូន	ឥណពន្ធ	ឥណទាន	ឥណយិក
		6058	ផ្សេងៗ	ឥណពន្ធ	ឥណទាន	ឥណយិក
	606		ថាមពល និងទឹក	ឥណពន្ធ	ឥណទាន	ឥណយិក
		6061	អគ្គីសនី	ឥណពន្ធ	ឥណទាន	ឥណយិក
		6062	ទឹក	ឥណពន្ធ	ឥណទាន	ឥណយិក
		6068	ផ្សេងៗ	ឥណពន្ធ	ឥណទាន	ឥណយិក
	608		សម្ភារៈផ្គត់ផ្គង់ផ្សេងៗ	ឥណពន្ធ	ឥណទាន	ឥណយិក
61	សេវាខាងក្រៅ					
	612		ការជួលមធ្យោបាយដឹកជញ្ជូន	ឥណពន្ធ	ឥណទាន	ឥណយិក
	613		ថ្លៃឈ្នួល និងបន្ទុក (អសង្ហារឹម)	ឥណពន្ធ	ឥណទាន	ឥណយិក
	614		សោប៊ីយបណ្តុះបណ្តាលបុគ្គលិកក្នុង និងក្រៅប្រទេស	ឥណពន្ធ	ឥណទាន	ឥណយិក
	615		ការថែទាំ និងជួសជុល	ឥណពន្ធ	ឥណទាន	ឥណយិក
		6152	ការថែទាំ និងជួសជុលអគារ	ឥណពន្ធ	ឥណទាន	ឥណយិក
		6156	ការថែទាំ និងជួសជុលមធ្យោបាយដឹកជញ្ជូន	ឥណពន្ធ	ឥណទាន	ឥណយិក

		6157	ការថែទាំ និងជួសជុលឧបករណ៍សម្ភារៈការិយាល័យសម្ភារៈពត៌មានវិទ្យា និងទូរគមនាគមន៍	ឥណពន្ធ	ឥណទាន	ឥណាយិក
	616		សោហ៊ុយធានារ៉ាប់រង	ឥណពន្ធ	ឥណទាន	ឥណាយិក
	617		សោហ៊ុយសិក្សាពិសោធន៍ សោហ៊ុយនៃការប្រើប្រាស់សេវា និង	ឥណពន្ធ	ឥណទាន	ឥណាយិក
		6171	សោហ៊ុយសិក្សាពិសោធន៍	ឥណពន្ធ	ឥណទាន	ឥណាយិក
		6172	សោហ៊ុយនៃការប្រើប្រាស់សេវា	ឥណពន្ធ	ឥណទាន	ឥណាយិក
		6173	សោហ៊ុយនៃការប្រើប្រាស់សិទ្ធិ	ឥណពន្ធ	ឥណទាន	ឥណាយិក
62	សេវាខាងក្រៅផ្សេងៗ					
	621		បុគ្គលិកខាងក្រៅ	ឥណពន្ធ	ឥណទាន	ឥណាយិក
		6211	ភ្នាក់ងារជាតិជាប់កិច្ចសន្យា	ឥណពន្ធ	ឥណទាន	ឥណាយិក
		6212	ភ្នាក់ងារបរទេសជាប់កិច្ចសន្យា	ឥណពន្ធ	ឥណទាន	ឥណាយិក
		6213	បុគ្គលិកសមូហភាពសាធារណៈផ្សេងៗ	ឥណពន្ធ	ឥណទាន	ឥណាយិក
	622		ទំនាក់ទំនងសាធារណៈ និងផ្សព្វផ្សាយ	ឥណពន្ធ	ឥណទាន	ឥណាយិក
		6221	សោហ៊ុយទទួលភ្ញៀវជាតិ	ឥណពន្ធ	ឥណទាន	ឥណាយិក
		6222	សោហ៊ុយទទួលភ្ញៀវបរទេស	ឥណពន្ធ	ឥណទាន	ឥណាយិក
		6223	ប្រជុំ សិក្ខាសាលា និងសន្និសីទ	ឥណពន្ធ	ឥណទាន	ឥណាយិក
		6224	ចំណាយពិធីបុណ្យ	ឥណពន្ធ	ឥណទាន	ឥណាយិក
		6225	ចំណាយសម្រាប់វត្តអនុស្សាវរីយ៍ក្នុង និងក្រៅប្រទេស	ឥណពន្ធ	ឥណទាន	ឥណាយិក
		6227	ការឃោសនា និងផ្សព្វផ្សាយពត៌មានសាធារណៈ	ឥណពន្ធ	ឥណទាន	ឥណាយិក
	623		សោហ៊ុយជាវសារពត៌មាន និងឯកសារ	ឥណពន្ធ	ឥណទាន	ឥណាយិក
	624		ចំណាយទូទាត់សោហ៊ុយក្នុងប្រទេស	ឥណពន្ធ	ឥណទាន	ឥណាយិក
		6241	សោហ៊ុយដឹកជញ្ជូន	ឥណពន្ធ	ឥណទាន	ឥណាយិក
		6242	សោហ៊ុយបេសកកម្ម	ឥណពន្ធ	ឥណទាន	ឥណាយិក
		6243	សោហ៊ុយស្នាក់នៅ	ឥណពន្ធ	ឥណទាន	ឥណាយិក
	625		ចំណាយទូទាត់សោហ៊ុយក្រៅប្រទេស	ឥណពន្ធ	ឥណទាន	ឥណាយិក
		6251	សោហ៊ុយដឹកជញ្ជូន	ឥណពន្ធ	ឥណទាន	ឥណាយិក
		6252	សោហ៊ុយបេសកកម្ម	ឥណពន្ធ	ឥណទាន	ឥណាយិក
		6253	សោហ៊ុយស្នាក់នៅ	ឥណពន្ធ	ឥណទាន	ឥណាយិក
	626		សោហ៊ុយប្រៃសណីយ៍ និងទូរគមនាគមន៍	ឥណពន្ធ	ឥណទាន	ឥណាយិក
		6261	សោហ៊ុយប្រៃសណីយ៍	ឥណពន្ធ	ឥណទាន	ឥណាយិក
		6262	សោហ៊ុយទូរគមនាគមន៍	ឥណពន្ធ	ឥណទាន	ឥណាយិក
	627		សោហ៊ុយធនាគារ	ឥណពន្ធ	ឥណទាន	ឥណាយិក
	628		សេវាខាងក្រៅផ្សេងៗទៀត	ឥណពន្ធ	ឥណទាន	ឥណាយិក
63	ពន្ធ និងអាករ					
	631		លពាបត្រ	ឥណពន្ធ	ឥណទាន	ឥណាយិក
	638		ពន្ធ និងអាករផ្សេងៗទៀត	ឥណពន្ធ	ឥណទាន	ឥណាយិក
64	បន្ទុកបុគ្គលិក					
	643		រង្វាន់ និងប្រាក់បំណាច់ផ្សេងៗ	ឥណពន្ធ	ឥណទាន	ឥណាយិក
		6438	ផ្សេងៗ	ឥណពន្ធ	ឥណទាន	ឥណាយិក
	644		លាភការ និងប្រាក់បំណាច់បុគ្គលិកមិនមែនក្របខណ្ឌ	ឥណពន្ធ	ឥណទាន	ឥណាយិក

		6441	ប្បៀវត្សមូលដ្ឋានបុគ្គលិកជាប់កិច្ចសន្យា	ឥណពន្ធ	ឥណទាន	ឥណាយិក
		6442	លាភការផ្សេង១ទៀតបុគ្គលិកជាប់កិច្ចសន្យា	ឥណពន្ធ	ឥណទាន	ឥណាយិក
	645		ប្រាក់វិភាជន៍សង្គម	ឥណពន្ធ	ឥណទាន	ឥណាយិក
		6451	ប្រាក់បំណាច់ជាលក្ខណៈគ្រួសារ	ឥណពន្ធ	ឥណទាន	ឥណាយិក
		6452	មន្ត្រីមានជំងឺ និងឧបត្ថម្ភអ្នកសម្រាលកូន	ឥណពន្ធ	ឥណទាន	ឥណាយិក
		6456	គ្រោះថ្នាក់ក្នុងការងារ និងទុព្វលភាព	ឥណពន្ធ	ឥណទាន	ឥណាយិក
		6458	ផ្សេង១	ឥណពន្ធ	ឥណទាន	ឥណាយិក
65	ឧបត្ថម្ភកធន និងជំនួយសង្គម					
	652		ឧបត្ថម្ភកធនដល់អង្គការសាធារណៈ	ឥណពន្ធ	ឥណទាន	ឥណាយិក
	658		ឧបត្ថម្ភកធនដល់អង្គភាពដែលមានលក្ខណៈសង្គម និង វប្បធម៌	ឥណពន្ធ	ឥណទាន	ឥណាយិក
		6584	ឧបត្ថម្ភកាកបាទក្រហម	ឥណពន្ធ	ឥណទាន	ឥណាយិក
66	បន្ទុកហិរញ្ញវត្ថុ					
	666		ខាតពីការប្តូរប្រាក់	ឥណពន្ធ	ឥណទាន	ឥណាយិក
	668		បន្ទុកហិរញ្ញវត្ថុផ្សេង១ទៀត	ឥណពន្ធ	ឥណទាន	ឥណាយិក
67	បន្ទុកពិសេស					
	675		តម្លៃគណនេយ្យនៃចំណែកសកម្មបានលក់ (តម្លៃនៅសល់)	ឥណពន្ធ	ឥណទាន	ឥណាយិក
68	ទាយជ្ជទានឱ្យដល់រំលស់អចលកម្ម					
	681		ទាយជ្ជទានឱ្យដល់រំលស់អចលកម្មអរូបី	ឥណពន្ធ	ឥណទាន	ឥណាយិក
	682		ទាយជ្ជទានឱ្យដល់រំលស់អចលកម្មរូបី	ឥណពន្ធ	ឥណទាន	ឥណាយិក
ថ្នាក់ ៧ : គណនី ចំណូល						
75	ការឧបត្ថម្ភ អំណោយ					
	751		ឧបត្ថម្ភកធនពីទ្វេភាគី	ឥណទាន	ឥណពន្ធ	ឥណទាយី
	752		ឧបត្ថម្ភកធនពីពហុភាគី	ឥណទាន	ឥណពន្ធ	ឥណទាយី
	753		ជំនួយផ្សេង១ទៀត	ឥណទាន	ឥណពន្ធ	ឥណទាយី
		7531	ឧបត្ថម្ភកធនពីថវិការដ្ឋសម្រាប់ដំណើរការ	ឥណទាន	ឥណពន្ធ	ឥណទាយី
		7532	ភាគទានពីរាជរដ្ឋាភិបាល	ឥណទាន	ឥណពន្ធ	ឥណទាយី
		7533	ភាគទានពីមន្ត្រីរាជការ	ឥណទាន	ឥណពន្ធ	ឥណទាយី
		7534	ឧបត្ថម្ភកធនពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា	ឥណទាន	ឥណពន្ធ	ឥណទាយី
		7535	ឧបត្ថម្ភកធនពីមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា	ឥណទាន	ឥណពន្ធ	ឥណទាយី
		7538	ឧបត្ថម្ភកធន និងចំណូលស្របច្បាប់ផ្សេងទៀត	ឥណទាន	ឥណពន្ធ	ឥណទាយី
76	ផលហិរញ្ញវត្ថុ			ឥណទាន	ឥណពន្ធ	ឥណទាយី
	761		ចំណូលពីការប្រាក់	ឥណទាន	ឥណពន្ធ	ឥណទាយី
	766		ចំណេញពីការប្តូរប្រាក់	ឥណទាន	ឥណពន្ធ	ឥណទាយី
	768		ផលហិរញ្ញវត្ថុផ្សេង១ទៀត	ឥណទាន	ឥណពន្ធ	ឥណទាយី
77	ផលផ្សេង១ និងផលពិសេស					
	775		ផលពីការលក់អចលកម្ម	ឥណទាន	ឥណពន្ធ	ឥណទាយី
	778		ផលពិសេសផ្សេង១ទៀត	ឥណទាន	ឥណពន្ធ	ឥណទាយី

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ឧបសម្ព័ន្ធ ២
ប្រព្រឹត្តិកម្មគណនី នៃប្លង់គណនេយ្យ របស់បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល

០១ - គណនី ទាយជ្ជទាន "លេខ ១០១"

គណនីនេះ បើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ជាធនធាន នៃតម្លៃអចលកម្មរូបី អចលកម្មរូបី អចលកម្មហិរញ្ញវត្ថុ បំណុលត្រូវសង ប្រាក់បានឱ្យខ្ចី និងធនធានផ្សេងទៀត របស់បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ដែលពុំទាន់បានកត់ត្រាទៅក្នុងលេខនៅគណនេយ្យ ។ តម្លៃនៃទ្រព្យសម្បត្តិ បំណុលខ្ចង់ត្រូវទារ ទាំងនេះ គឺបានមកពីតារាងវាយតម្លៃនៅលើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិ និងតារាងស្ថានភាពបំណុល និងតារាងស្ថានភាពទឹកប្រាក់ត្រូវទារដែលមានការពាក់ព័ន្ធលើការគ្រប់គ្រងខ្ចង់ប្រាក់ទាំងនោះ ។

ការកត់ត្រា :
ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ត្រូវសងដែលបានធ្វើសមាហរណកម្ម
ឥណទាន :- កត់ត្រាតម្លៃអចលកម្ម និងប្រាក់ឱ្យខ្ចីដែលបានធ្វើសមាហរណកម្ម
- កត់ត្រាចំនួនទឹកប្រាក់ដែលជាធនធាន ដែលបានផ្ទេរមកពីគណនីអកម្មផ្សេងទៀត
សមតុល្យ : ឥណទាយី បង្ហាញតំលៃអចលកម្ម ប្រាក់ឱ្យខ្ចី និងធនធានផ្សេងទៀតមានពីមុនមកដែលជាធនធានរបស់បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ។

០២ - គណនី អតិរេកចរន្តប្រើសម្រាប់ចំណាយវិនិយោគ "លេខ ១០៦"

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ នៃអតិរេកថវិកាផ្នែកចរន្តដែលបានប្រើប្រាស់សម្រាប់ចំណាយវិនិយោគ ។

ការកត់ត្រា :
ឥណពន្ធ : ពុំមានប្រតិបត្តិការ
ឥណទាន : កត់ត្រាចំនួនទឹកប្រាក់អតិរេកផ្នែកចរន្តដែលបានប្រើប្រាស់សម្រាប់ចំណាយវិនិយោគ ដោយកត់ត្រាបដិភាគ និងគណនីយោងជាថ្មី
សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់នៃអតិរេកផ្នែកចរន្តដែលបានប្រើប្រាស់សម្រាប់ចំណាយវិនិយោគបួកបន្ត ។
<u>ចំណាំ</u> : តួលេខចលនាខាងឥណទាននៃគណនី ចំណែកនៃអតិរេកចរន្តបានប្រើសម្រាប់ចំណាយវិនិយោគនេះ គឺស្មើនឹងតួលេខចំណាយវិនិយោគក្នុងឆ្នាំ ។

០៣ - គណនី យោងជាថ្មី ឥណទាយី (អតិរេក) "លេខ ១១០"

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ដែលបានផ្ទេរមកពីគណនីលទ្ធផល នៃការិយបរិច្ឆេទ នៃការអនុវត្តថវិការបស់បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ។

ការកត់ត្រា :
ឥណពន្ធ :- កត់ត្រាចំនួនទឹកប្រាក់ នៃអតិរេកថវិកាចរន្តដែលបានប្រើសម្រាប់ចំណាយវិនិយោគ
- កត់ត្រាចំនួនទឹកប្រាក់ នៃលទ្ធផលឱនភាពថវិកាចរន្តដែលបានផ្ទេរមក
ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ នៃលទ្ធផលអតិរេកថវិកាដែលបានផ្ទេរមក
សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់អតិរេកថវិកាបួកបន្តដែលពុំទាន់បានប្រើប្រាស់
<u>ចំណាំ</u> : ការជម្រះផ្ទេរលទ្ធផលពីគណនីលទ្ធផល នៃការិយបរិច្ឆេទមកគណនីយោងជាថ្មី គឺនៅក្នុងឆ្នាំបន្ទាប់ ។

០៤ - គណនី លទ្ធផល នៃការិយបរិច្ឆេទ (អតិរេក-ឱនភាព) "លេខ ១២១"

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាការគណនារកលទ្ធផល នៃការិយបរិច្ឆេទ នៃការអនុវត្តថវិកាដោយផ្ទេរសមតុល្យចុងឆ្នាំ នៃគណនីចំណូល និងគណនីចំណាយថវិកាមកគណនីនេះ ។

ផ្ទះលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

ការកត់ត្រា :
ឥណពន្ធ :- កត់ត្រាផ្ទេរសមតុល្យឥណយិក នៃគណនីចំណាយថវិកាចរន្ត
- កត់ត្រាផ្ទេរលទ្ធផលអតិរេកចូលគណនី យោងជាថ្មី
ឥណទាន :- កត់ត្រាផ្ទេរសមតុល្យឥណទាយី នៃគណនីចំណូលថវិកាចរន្ត
- កត់ត្រាផ្ទេរលទ្ធផលឱនភាពចូលគណនីយោងជាថ្មី
សមតុល្យ :- ឥណយិក បង្ហាញលទ្ធផលឱនភាព នៃការអនុវត្តន៍ថវិកាចរន្ត ដែលពុំទាន់បានចាត់ចែង
- ឥណទាយី បង្ហាញលទ្ធផលអតិរេក នៃការអនុវត្តន៍ថវិកាចរន្ត ដែលពុំទាន់បានចាត់ចែង
<u>ចំណាំ</u> : ការដម្រះសមតុល្យ នៃគណនីនេះ គឺធ្វើនៅឆ្នាំបន្ទាប់ ។

០៥ - គណនី សោហ៊ុយសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍ - លេខ ២០៣ -

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ដែលបានចំណាយលើការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍ ។
ការកត់ត្រា :
ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានចំណាយលើការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍ
ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយលើការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍ ដែលបានជម្រះជាមួយនឹងទឹកប្រាក់រំលស់បូកបន្ត និងតម្លៃនៅសល់
សមតុល្យ : ឥណយិក បង្ហាញតម្លៃ នៃការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍កំពុងមាន ។
<u>ចំណាំ</u> : គណនីលេខ ២០៣ ត្រូវចែកទៅជាអនុគណនី សម្រាប់សោហ៊ុយសិក្សា ស្រាវជ្រាវ និងអភិវឌ្ឍ ។

០៦ - គណនី ប្រកាសនីយបត្រ អាជ្ញាបណ្ណ និងសិទ្ធិប្រហាក់ប្រហែល - លេខ២០៥-

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ដែលបានចំណាយដើម្បីបង្កើត ឬទិញប្រកាសនីយបត្រអាជ្ញាប័ណ្ណ ម៉ាកសម្គាល់ សិទ្ធិប្រហាក់ប្រហែល និងកម្មវិធីកុំព្យូទ័រ ។
ការកត់ត្រា :
ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានទិញបង្កើតប្រកាសនីយបត្រ អាជ្ញាប័ណ្ណ ម៉ាកសម្គាល់សិទ្ធិប្រហាក់ប្រហែល និងកម្មវិធីកុំព្យូទ័រ
ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ នៃប្រកាសនីយបត្រ អាជ្ញាប័ណ្ណ ម៉ាកសម្គាល់សិទ្ធិប្រហាក់ប្រហែល និងកម្មវិធីកុំព្យូទ័រ ដែលបានបន្ថយដោយលក់ធ្វើអំណោយផ្ទេរ ឬជម្រះ
សមតុល្យ : ឥណយិកបង្ហាញតម្លៃប្រកាសនីយបត្រអាជ្ញាប័ណ្ណ ម៉ាកសម្គាល់ សិទ្ធិប្រហាក់ប្រហែល និងកម្មវិធីកុំព្យូទ័រ ដែលកំពុងមាន ។
<u>ចំណាំ</u> : គណនីនេះត្រូវចែកទៅជាអនុគណនីសម្រាប់ប្រកាសនីយបត្រ អាជ្ញាបណ្ណ សិទ្ធិប្រហាក់ប្រហែល កម្មវិធីកុំព្យូទ័រ និងសោហ៊ុយផ្សេងៗទៀត ។

០៧ - គណនី ដីធ្លី ដីព្រៃ និង សម្បត្តិធម្មជាតិផ្សេងៗ - លេខ ២១១-

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រានូវតម្លៃដីធ្លី ដែលបានទិញពីអំណោយ និងបានពីរូបភាពផ្សេងទៀត ហើយបានបញ្ចូលជាទ្រព្យសម្បត្តិរបស់បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ។
ការកត់ត្រា :
ឥណពន្ធ : កត់ត្រាតម្លៃដីធ្លី ដែលបានបញ្ចូលជាទ្រព្យសម្បត្តិរបស់បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល
ឥណទាន : កត់ត្រាតម្លៃដីធ្លី ដែលបានបន្ថយដោយ លក់ អំណោយ ផ្ទេរ ឬជម្រះ
សមតុល្យ : ឥណយិក បង្ហាញតម្លៃដីធ្លីដែលកំពុងមាន ។
<u>ចំណាំ</u> : អនុគណនីដីធ្លី (លេខ ២១១១) ពុំមានការគិតរំលស់ទេ ។

០៨ - គណនី ការរៀបចំកែលម្អ ដីធ្លី ដីព្រៃ និងសម្បត្តិធម្មជាតិផ្សេងៗ - លេខ ២១២ -

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ដែលបានចំណាយលើការរៀបចំកែលម្អដីធ្លី ។
ការកត់ត្រា :
ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានចំណាយលើការកែលម្អដីធ្លី

- ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ដែលបានជម្រះជាមួយនឹងទឹកប្រាក់រំលស់បូកបន្ត និងគណនីតម្លៃគណនេយ្យ នៃចំណែកសកម្មដែលបានលក់ ឬជម្រះ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ដែលបានចំណាយលើការកែលម្អដីធ្លីដែលពុំទាន់បានជម្រះ ។

០៩ - គណនី សំណង់ និងការរៀបចំកែលម្អ អគារ - លេខ ២១៣ -

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ដែលបានចំណាយលើការទិញ ការសាងសង់ និងការកែលម្អអាគារ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានចំណាយលើការទិញ ការសាងសង់ និងការកែលម្អអាគារ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ដែលបានជម្រះជាមួយនឹងទឹកប្រាក់រំលស់បូកបន្ត និងគណនីតម្លៃគណនេយ្យ នៃចំណែកសកម្មដែលបានលក់ ឬជម្រះ ឬផ្ទេរ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់នៃតម្លៃអាគារដែលបានចំណាយលើការទិញ ការសាងសង់ និងចំនួនទឹកប្រាក់ចំណាយលើការកែលម្អអាគារ ។

<u>ចំណាំ</u> : គណនីនេះត្រូវចែកទៅជាអនុគណនីសម្រាប់សំណង់អាគារ ការរៀបចំកែលម្អអគារ និងសំណង់ផ្សេងៗ។

១០ - គណនី បំបនកម្មបច្ចេកទេស សម្ភារៈ និងហត្ថបករណ៍ - លេខ ២១៥ -

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រានូវតម្លៃបំបនកម្មបច្ចេកទេស សម្ភារៈ ហត្ថបករណ៍ដែលបានពីការទិញ ពីអំណោយ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាតម្លៃបំបនកម្មបច្ចេកទេស សម្ភារៈ និងហត្ថបករណ៍ដែលបានបញ្ចូលជាទ្រព្យសម្បត្តិរបស់បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល

ឥណទាន : កត់ត្រាតម្លៃបំបនកម្មបច្ចេកទេស សម្ភារៈ និងហត្ថបករណ៍ដែលបានបន្ថយដោយលក់ ធ្វើអំណោយ ជម្រះ ឬផ្ទេរ

សមតុល្យ : ឥណាយិក បង្ហាញតម្លៃបំបនកម្មបច្ចេកទេស សម្ភារៈ ហត្ថបករណ៍ ដែលកំពុងមាន ។

<u>ចំណាំ</u> : គណនីនេះត្រូវចែកទៅជាអនុគណនីសម្រាប់បំបនកម្មបច្ចេកទេសសម្ភារៈ គ្រឿងឧបករណ៍ (ហត្ថបករណ៍) និងគ្រឿងសម្ភារៈផ្សេងៗ ។

១១ - គណនី អចលកម្មរូបី ផ្សេងៗ - លេខ ២១៨ -

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រានូវតម្លៃអចលកម្មរូបីផ្សេងៗដែលបានពីទិញ អំណោយ និងពីការផលិត ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាតម្លៃអចលកម្មរូបី ដែលបានបញ្ចូលជាទ្រព្យសម្បត្តិរបស់បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល

ឥណទាន : កត់ត្រាតម្លៃអចលកម្មរូបីដែលបានបន្ថយដោយលក់ អំណោយ ផ្ទេរ ឬជម្រះ

សមតុល្យ : ឥណាយិក បង្ហាញតម្លៃអចលកម្មរូបីផ្សេងៗដែលកំពុងមាន ។

<u>ចំណាំ</u> : គណនីនេះត្រូវចែកទៅជាអនុគណនីសម្រាប់សម្ភារៈឧបករណ៍ដឹកជញ្ជូន សម្ភារៈឧបករណ៍ការិយាល័យ សម្ភារៈព័ត៌មានវិទ្យា និងទូរគមនាគមន៍ សង្ហារឹម និងអចលកម្មរូបីផ្សេងទៀត ។

១២ - គណនី អចលកម្មកំពុងដំណើរការ - លេខ ២៣១ -

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រានូវតម្លៃអចលកម្មរូបីដែលកំពុងដំណើរការសាងសង់ ផលិត ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាតម្លៃអចលកម្មរូបី ដែលកំពុងដំណើរការសាងសង់ ផលិត

ឥណទាន : កត់ត្រាតម្លៃអចលកម្មរូបី ដែលបានផ្ទេរទៅគណនី អចលកម្មរូបី ដែលពាក់ព័ន្ធ

សមតុល្យ : ឥណាយិក បង្ហាញតម្លៃអចលកម្មរូបី ដែលកំពុងដំណើរការសាងសង់-ផលិត ។

<u>ចំណាំ</u> : គណនីលេខ ២៣១ ត្រូវចែកទៅជាអនុគណនីសម្រាប់ការកែលម្អ ដីធ្លី អគារ បំបនកម្មបច្ចេកទេស ។

១៣ - គណនី មូលបត្រនៃតាគកម្ម - លេខ ២៦១ -

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់បានចំណាយលើការវិនិយោគលើមូលបត្រជាមួយសហគ្រាស ក្រែមហ៊ុន ឬស្ថាប័នហិរញ្ញវត្ថុ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានវិនិយោគលើមូលបត្រ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់មូលបត្រដែលបានលក់ ឬជម្រះ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ដែលបានវិនិយោគលើមូលបត្រ ដែលពុំទាន់បានជម្រះឬលក់ចេញ។
ចំណាំ :- គណនីនេះ ត្រូវតែមានលម្អិតទៅតាមប្រភេទមូលបត្រដែលបានវិនិយោគ ។
- ចំនួនទឹកប្រាក់ដែលកត់ត្រាក្នុងគណនីនេះ គឺទាក់ទងតែនឹងប្រាក់ដើមតែប៉ុណ្ណោះ ។

១៤ - គណនី ការឱ្យខ្ចី "លេខ ២៧១"

ការកត់ត្រា : គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ដែលបានផ្តល់ឱ្យអង្គភាព ស្ថាប័នផ្សេងៗខ្ចីប្រាក់ ។ ការកត់ត្រាក្នុងគណនីនេះតែចំនួនទឹកប្រាក់ដើមដែលបានឱ្យខ្ចី និងបានសងមកវិញ ។

ការកត់ត្រា :
ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដើមដែលបានឱ្យខ្ចី
ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ដើមដែលបានសងមកវិញ
សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ឱ្យខ្ចីដែលពុំទាន់បានសងមកវិញ ។

១៥ - គណនី រំលស់អចលកម្មអរូបី "លេខ ២៨០"

ការកត់ត្រា : គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់រំលស់អចលកម្មអរូបី ។ គណនីនេះកត់ត្រាបដិភាគ និងគណនីទាយជួទានឱ្យដល់រំលស់អចលកម្មអរូបី ។

ការកត់ត្រា :
ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់រំលស់អចលកម្មអរូបីដែលបានជម្រះជាមួយតម្លៃអចលកម្មអរូបី
ឥណទាន : កត់ត្រាចំនួនទឹកប្រាក់រំលស់អចលកម្មអរូបីក្នុងឆ្នាំដែលបានចាត់ជាចំណាយថវិកាចរន្ត
សមតុល្យ : ឥណទាយីបង្ហាញចំនួនទឹកប្រាក់រំលស់អចលកម្មអរូបីបូកបន្ត ។
ចំណាំ :- គណនីលេខ ២៨០ ត្រូវចែកទៅជាអនុគណនីសម្រាប់រំលស់ទៅតាមប្រភេទអចលកម្ម ។
- ការជម្រះចំនួនទឹកប្រាក់ខាងឥណពន្ធនៃគណនីរំលស់អចលកម្មអរូបីយោងលើការលក់ចេញ ការបោះបង់ចោល ការបាត់បង់ និងការផ្ទេរ ។
- ករណីដែលចំនួនទឹកប្រាក់រំលស់បូកបន្តនៃអចលកម្មស្មើនឹងតម្លៃបញ្ចូល គឺត្រូវបញ្ឈប់ការធ្វើទាយជួទានរំលស់ ។ ការជម្រះលុះត្រាតែអចលកម្មនោះឈប់ប្រើប្រាស់ ។

១៦ - គណនី រំលស់អចលកម្មរូបី "លេខ ២៨១"

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់រំលស់អចលកម្មរូបី ។ គណនីនេះកត់ត្រាបដិភាគ និងគណនីទាយជួទានឱ្យដល់រំលស់អចលកម្មរូបី ។

ការកត់ត្រា :
ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់រំលស់អចលកម្មរូបីដែលបានជម្រះជាមួយតម្លៃអចលកម្មរូបី
ឥណទាន : កត់ត្រាចំនួនទឹកប្រាក់រំលស់អចលកម្មរូបីក្នុងឆ្នាំដែលបានចាត់ជាចំណាយថវិកាចរន្ត
សមតុល្យ : ឥណទាយីបង្ហាញចំនួនទឹកប្រាក់រំលស់អចលកម្មរូបីបូកបន្ត ។
ចំណាំ :- គណនីលេខ ២៨០ ត្រូវចែកទៅជាអនុគណនីសម្រាប់រំលស់ទៅតាមប្រភេទអចលកម្ម ។
- ការជម្រះចំនួនទឹកប្រាក់ខាងឥណពន្ធនៃគណនីរំលស់អចលកម្មរូបីយោងលើការលក់ចេញ ការបោះបង់ចោល ការបាត់បង់ និងការផ្ទេរ ។
- ករណីដែលចំនួនទឹកប្រាក់រំលស់បូកបន្ត នៃអចលកម្មស្មើនឹងតម្លៃបញ្ចូល គឺត្រូវបញ្ឈប់ការធ្វើទាយជួទានរំលស់ ។ ការជម្រះលុះត្រាតែអចលកម្មនោះ ឈប់ប្រើប្រាស់ ។

១៧ - គណនីអ្នកជួតផ្គង់ ធំនិញ សេវា ការងារ "លេខ ៤០១"

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ដែលត្រូវទូទាត់សងទៅអ្នកផ្គត់ផ្គង់ទំនិញ ផ្តល់សេវាកម្ម ការងារដោយយោងតាមអាណត្តិបើកប្រាក់ និងការបង្វែរមកពីប្រភពផ្សេងៗ ។

ការកត់ត្រា :
ឥណពន្ធ :- កត់ត្រាចំនួនទឹកប្រាក់ដែលបានបើកផ្តល់ជូនអត្ថគាហក:
- កត់ត្រាចំនួនទឹកប្រាក់ដែលបានកាត់ទុកទូទាត់ទៅមុខសញ្ញាផ្សេង
ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ដែលត្រូវសងទៅអ្នកផ្គត់ផ្គង់ទំនិញ សេវា ការងារតាមអាណត្តិបើកប្រាក់ ឬបង្វែរពីគណនីផ្សេងមក
សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ដែលត្រូវសងទៅអ្នកផ្គត់ផ្គង់ ។
ចំណាំ : គណនីលេខ ៤០១ ត្រូវតាមដានលម្អិតទៅតាមអ្នកផ្គត់ផ្គង់នីមួយៗ ។

១៨ - គណនី អ្នកជួតផ្គង់អចលកម្ម "លេខ ៤០៤"

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ដែលត្រូវទូទាត់សងទៅអ្នកផ្គត់ផ្គង់អចលកម្ម ដោយយោងតាមអាណត្តិបើកប្រាក់ ឬលិខិតផ្សេងទៀតដែលមានតម្លៃប្រហាក់ប្រហែល ។

ការកត់ត្រា :
ឥណពន្ធ :- កត់ត្រាចំនួនទឹកប្រាក់ដែលបានបើកផ្តល់ជូនអតិថិជន
- កត់ត្រាចំនួនទឹកប្រាក់ដែលបានកាត់ទុកទូទាត់ទៅមុខសញ្ញាផ្សេង
ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ដែលត្រូវសងទៅអ្នកផ្តត់ផ្តង់អចលកម្ម តាមអាណត្តិបើកប្រាក់ ឬលិខិតដែលមានតម្លៃប្រហាក់ប្រហែល ឬបង្វែរពីគណនីផ្សេងមក
សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់បំណុលដែលត្រូវសងទៅអ្នកផ្តត់ផ្តង់ ។
ចំណាំ : គណនីលេខ ៤០៤ ត្រូវតាមដានលម្អិតទៅតាមអ្នកផ្តត់ផ្តង់នីមួយៗ ។

១៩ - គណនី ការកាត់ទុក ការជំនាស - លេខ ៤០៧ -

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ដែលបានកាត់ទុកពីចំនួនទឹកប្រាក់ត្រូវសងទៅអ្នកផ្តត់ផ្តង់ មន្ត្រីរាជការ បុគ្គលិក សម្រាប់សងទៅមុខសញ្ញាផ្សេងៗ យោងតាមការសម្រេចរបស់តុលាការ ឬអាជ្ញាធរដែលមានសមត្ថកិច្ច ។

ការកត់ត្រា :
ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ ដែលបានសងទៅអ្នកទទួលផល ពីការកាត់ទុកក្រោមរូបភាពជាសាច់ប្រាក់បង្វែរ ឬជាមូលប្បទានប័ត្រ
ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ដែលបានកាត់ចេញពីចំនួនទឹកប្រាក់ដែលត្រូវទូទាត់ជូនទៅអ្នកផ្តត់ផ្តង់ មន្ត្រីរាជការ បុគ្គលិក
សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ដែលបានកាត់ទុក ហើយពុំទាន់បានសងទៅអ្នកទទួលផលពីការកាត់ទុក ។
ចំណាំ : គណនីលេខ ៤០៧ ត្រូវតាមដានលម្អិតទៅតាមអ្នកទទួលផលពីការកាត់ទុក ។

២០ - គណនី អ្នកផ្តត់ផ្តង់ ឥណយិក - លេខ ៤០៩ -

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ដែលបានបើកផ្តល់មុនទៅអ្នកផ្តត់ផ្តង់ សម្ភារៈ សេវា និងទំនិញ ។ គណនីនេះត្រូវទូទាត់កាត់កងជាមួយនឹងគណនីអ្នកផ្តត់ផ្តង់នៅពេលមានអាណត្តិបើកប្រាក់ត្រូវទូទាត់ទៅអ្នកទាំងនោះ ។

ការកត់ត្រា :
ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ ដែលបានផ្តល់មុនជូនទៅអ្នកផ្តត់ផ្តង់ជាសាច់ប្រាក់ ជាមូលប្បទានប័ត្រ ឬដោយបង្វែរ
ឥណទាន :- កត់ត្រាចំនួនទឹកប្រាក់ ដែលបានកាត់កងជាមួយនឹងចំនួនទឹកប្រាក់ ដែលត្រូវសងទៅអ្នកផ្តត់ផ្តង់
- កត់ត្រាចំនួនទឹកប្រាក់ដែលអ្នកផ្តត់ផ្តង់បានបង្វិលសងមកវិញ
សមតុល្យ : ឥណយិក បង្ហាញចំនួនទឹកប្រាក់ត្រូវទារពីអ្នកផ្តត់ផ្តង់ ។
ចំណាំ :- គណនីលេខ ៤០៩ ពុំមានគំរូហត្ថលេខារបស់ម្ចាស់គណនីទេ គឺជាប្រភេទគណនីរង់ចាំ ។
- គណនីនេះត្រូវតាមដានលម្អិតទៅតាមអ្នកផ្តត់ផ្តង់ ។

២១ - គណនី ប្រាក់ប្បៀវត្ស និងលាភការត្រូវសង - លេខ ៤២១ -

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ប្បៀវត្សលាភការ រង្វាន់ ប្រាក់វិភាជន៍សង្គម និងប្រាក់បំណាច់ផ្សេងៗ ដែលត្រូវសងទៅក្រុមប្រឹក្សាភិបាល បុគ្គលិកក្របខណ្ឌអចិន្ត្រៃយ៍ និងបុគ្គលិកមិនមែនក្របខណ្ឌ យោងតាមអាណត្តិបើកប្រាក់ ។

ការកត់ត្រា :
ឥណពន្ធ :- កត់ត្រាចំនួនទឹកប្រាក់ប្បៀវត្សនិងលាភការដែលបានសង
- កត់ត្រាចំនួនទឹកប្រាក់ប្បៀវត្សនិងលាភការដែលបានកាត់ទុកត្រូវសងទៅមុខសញ្ញាផ្សេង
ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ប្បៀវត្សនិងលាភការដែលត្រូវសង
សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ប្បៀវត្សនិងលាភការដែលពុំទាន់បានបើកផ្តល់ ។
ចំណាំ : គណនីលេខ ៤២១ មានគំរូហត្ថលេខារបស់ម្ចាស់គណនីដែលជាភ្នាក់ងារបើកផ្តល់ ។

២២ - គណនី សោហ៊ុយបេសកកម្ម និងសោហ៊ុយផ្សេងៗត្រូវសង - លេខ ៤២២ -

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ សោហ៊ុយបេសកកម្ម និងសោហ៊ុយផ្សេងៗដែលត្រូវសងទៅក្រុមប្រឹក្សាភិបាល បុគ្គលិកក្របខណ្ឌអចិន្ត្រៃយ៍ និងបុគ្គលិក មិនមែនក្របខណ្ឌតាមរយៈរដ្ឋទេយ្យករបុរេប្រទាន ។

ការកត់ត្រា :
ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់សោហ៊ុយបេសកកម្ម និងសោហ៊ុយផ្សេងៗ ដែលបានបើកផ្តល់ជាសាច់ប្រាក់ មូលប្បទានប័ត្រ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់សោហ៊ុយបេសកកម្ម និងសោហ៊ុយផ្សេងៗដែលត្រូវបើកផ្តល់
សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់សោហ៊ុយបេសកកម្ម និងសោហ៊ុយផ្សេងៗ ដែលត្រូវសង ។
ចំណាំ : គណនីលេខ ៤២២ ពុំចាំបាច់មានសំរុហាគ្រលេខារបស់ម្ចាស់គណនីទេ ។

២៣ - គណនី ប្រាក់តម្កល់ធានារ៉ាប់រងសង្គមសាធារណៈ - លេខ ៤៦២ -

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ដែលអ្នកផ្គត់ផ្គង់ អ្នកមៅការ បានបង់សម្រាប់តម្កល់ធានាលើការដេញថ្លៃ និងការអនុវត្តន៍កិច្ចសន្យា ។

ការកត់ត្រា :
ឥណពន្ធ :- កត់ត្រាចំនួនទឹកប្រាក់តម្កល់ធានាដែលសងជាសាច់ប្រាក់ មូលប្បទានប័ត្រ ឬបង្វែរ
- កត់ត្រាចំនួនទឹកប្រាក់តម្កល់ធានា ដែលបានបង្វែរចូលថវិការបស់បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល
ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលពីប្រាក់តម្កល់ធានាដែលបានទទួលជាសាច់ប្រាក់ មូលប្បទានប័ត្រ ឬបង្វែរ
សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់តម្កល់ធានាដែលត្រូវសង ។
ចំណាំ : គណនីនេះត្រូវចែកទៅជាអនុគណនីទៅតាមអ្នកដេញថ្លៃនីមួយៗ ។

២៤ - គណនី ឥណាយិកផ្សេងៗ - លេខ ៤៦៣ -

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ត្រូវទារ ឬត្រូវដោះស្រាយផ្សេងៗ ។

ការកត់ត្រា :
ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ផ្សេងៗត្រូវទារ ឬត្រូវដោះស្រាយ
ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ផ្សេងៗដែលបានដោះស្រាយ
សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ផ្សេងៗត្រូវទារ ឬត្រូវដោះស្រាយ ។
ចំណាំ :- គណនីលេខ ៤៦៣ ត្រូវសូន្យសមតុល្យនៅដំណាច់ឆ្នាំនីមួយៗ ។
- គណនីនេះ ជាប្រភេទគណនីរង់ចាំ ។

២៥ - គណនី ឥណទាយីផ្សេងៗ - លេខ ៤៦៥ -

អនុគណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជាការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ត្រូវសងផ្សេងៗ ក្រៅពីចំណូលត្រូវសងទៅឱ្យអ្នកផ្គត់ផ្គង់ ក្រសួង មន្ទីរ អង្គភាព និងចំនួនទឹកប្រាក់ត្រូវដោះស្រាយ ។ គណនីលេខ ៤៦៥ ជាប្រភេទគណនីចម្លង ។

ការកត់ត្រា :
ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ផ្សេងៗបានសង ឬបានដោះស្រាយ
ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ផ្សេងៗត្រូវសង ឬត្រូវដោះស្រាយ
សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ផ្សេងៗត្រូវសង ឬត្រូវដោះស្រាយ ។

២៦ - អនុគណនី ចំណូលផ្សេងៗ និងបង្វែររង់ចាំដោះស្រាយ - លេខ ៤៧០.៨ -

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជាការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលផ្សេងៗ ឬចំនួនទឹកប្រាក់ដែលត្រូវបង្វែរទៅគណនីអកម្មផ្សេងទៀត ។ អនុគណនីលេខ ៤៧០ ៨ ស្ថិតនៅក្នុងគណនីចំណូលត្រូវនិយ័តភាព ។

ការកត់ត្រា :
ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលផ្សេងៗ និងបង្វែរបានដោះស្រាយ
ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលផ្សេងៗ និងបង្វែររង់ចាំដោះស្រាយ
សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ចំណូលរង់ចាំការបង្វែរ និងការដោះស្រាយ ។

២៧ - អនុគណនី ចំណាយផ្សេងៗរង់ចាំការដោះស្រាយ - លេខ ៤៧២.៨ -

អនុគណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយ ឬមានលក្ខណៈប្រហាក់ប្រហែលដែលរង់ចាំការដោះស្រាយ ឬផ្ទេរទៅគណនីសកម្មផ្សេងទៀត ។ គណនីលេខ ៤៧២.៨ ស្ថិតនៅក្នុងគណនីចំណាយរង់ចាំនិយ័តកម្ម (លេខ ៤៧២) និងជាប្រភេទគណនីរង់ចាំ ។

ការកត់ត្រា :
ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណាយរង់ចាំការដោះស្រាយ
ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយបានដោះស្រាយ
សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយរង់ចាំការដោះស្រាយ ។
ចំណាំ : អនុគណនីលេខ ៤៧២.៨ ត្រូវចែកជាអនុគណនីរងសម្រាប់មុខសញ្ញានីមួយៗ ។

- ២៨ - **គណនី ចំណាយជាបណ្តោះអាសន្ន (បុរេប្រទានសាច់ប្រាក់) សម្រាប់ដំណើរការ - លេខ ៤៧៣ -**

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ដែលបានចំណាយជាបណ្តោះអាសន្នលើការផ្តល់ប្រាក់បុរេប្រទាន ទៅមន្ត្រីរាជការដោយយោងតាមលិខិតសម្រេចរបស់នាយកបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានផ្តល់បុរេប្រទាន

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ដែលបានទូទាត់បុរេប្រទានដោយអាណត្តិបើកប្រាក់ ឬជាសាច់ប្រាក់

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បុរេប្រទានដែលពុំទាន់បានទូទាត់។

<u>ចំណាំ</u> :- គណនីលេខ ៤៧៣ ត្រូវតាមដានលម្អិតទៅតាមអ្នកទទួលប្រាក់បុរេប្រទាននីមួយៗ

- គណនីនេះត្រូវសូន្យសមតុល្យនៅដំណាច់ឆ្នាំ ។

២៩ - គណនី ចំណូលបានឧទ្ទូលពុំទាន់មានសណាកបត្រ - លេខ ៤៧៤ -

គណនីនេះបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលបានទទួលហើយនៅរង់ចាំសណាកប័ត្របង់ជាចំណូលថវិកា ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលបានបង្វែរចូលថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលរង់ចាំសណាកប័ត្រ

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់រង់ចាំការបង្វែរចូលថវិកា ។

<u>ចំណាំ</u> : គណនីនេះត្រូវសូន្យសមតុល្យ នៅដំណាច់ឆ្នាំ ។

៣០ - គណនី ចរន្តជារ្រាក់រៀលនៅធនាគារជាតិ នៃកម្ពុជា និងនៅសាខា - លេខ ៥១០ -

